# វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

## របាយការណ៍សង្ខេប
## សមិទ្ធផលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្មឆ្នាំ២០១៥
## និងទិសដៅសម្រាប់ឆ្នាំ២០១៦-២០១៨









ការស្រាវជ្រាវ → ការផ្សព្វផ្សាយ → ផលិតកម្ម → ទីផ្សារ

# អារម្ភកថា

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាគឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមាននីតិបុគ្គលភាពនិងស្វ័យភាពហិរញ្ញវត្ថុ។ វិទ្យាស្ថានស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអាណាព្យាបាលហិរញ្ញវត្ថុ (អនុក្រឹត្យលេខ៧៤អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩)។ វិទ្យាស្ថានត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិយ៉ាងទូលំទូលាយ ដើម្បីបំពេញបេសកកម្មក្នុងនាមវិទ្យាស្ថាន ក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃអនុក្រឹត្យនិងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ វិទ្យាស្ថានគ្រប់គ្រងដោយនាយកមួយរូបនិងមាននាយករងមួយចំនួនជាជំនួយការ។ បេសកកម្មរបស់វិទ្យាស្ថានគឺ បង្កើនផលិតភាពដំណាំកសិកម្ម បសិដ្ឋកម្មពិពិធកម្មដំណាំ និងធានានូវនិរន្តរភាពបរិស្ថាន និងស្ថេរភាពជីវភាពជនបទតាមរយៈភាពជាដៃគូលើកិច្ចការស្រាវជ្រាវនិងប្រើប្រាស់បច្ចេកវិទ្យា។ វិទ្យាស្ថានមានសមត្ថភាពល្បីល្បាញខាងការអភិវឌ្ឍន៍សមត្ថភាពក្នុងផលិតកម្មស្រូវហើយក៏ត្រូវបានពង្រីកសមត្ថភាពស្រាវជ្រាវរបស់ខ្លួនលើដំណាំចម្ការផងដែរ។

វិទ្យាស្ថានមានកិត្តិយសផ្តល់ជូននូវរបាយការណ៍សង្ខេបប្រចាំឆ្នាំ២០១៥ បង្ហាញនូវលទ្ធផលនិងសមិទ្ធផលនៃការស្រាវជ្រាវ ក្នុងការអនុវត្តន៍តាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម២០១៤–២០១៨ ហើយដែលជាស្នាដៃនៃការស្រាវជ្រាវរបស់អង្គភាពចំណុះរបស់ខ្លួនរួមមាន រុក្ខជម្រើសវិទ្យា វិទ្យាសាស្ត្រដីនិងទឹក ការពារដំណាំ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រសេដ្ឋកិច្ចសង្គម ប្រព័ន្ធកសិកម្ម និងបណ្តុះបណ្តាលនិងព័ត៌មានវិទ្យា។ របាយការណ៍នេះត្រូវបានផលិតឡើងក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន ដោយមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយមន្ត្រីរដ្ឋាភិបាលពីថ្នាក់ជាតិនិងក្រោមជាតិ ក្នុងនោះមាន ថ្នាក់ដឹកនាំនិងមន្ត្រីបច្ចេកទេសនៃអគ្គនាយកដ្ឋានកសិកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម មន្ទីរកសិកម្មរាជធានីខេត្ត អង្គភាពជំនាញរបស់ក្រសួង ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងស្ថាប័នអប់រំនិងស្រាវជ្រាវអន្តរជាតិជាច្រើនទៀតមានដូចជា ACIAR, IRRI, University of Queensland, CSIRO, Murdoch University, Charles Sturt University, University of South Australia, University of Western Sydney, NSW DPI, Tamworth Agricultural Institute, RDA, KOPIA-Cambodia, NIAS, YAAS, Bioversity International, MJP, និងជាពិសេសកសិករកម្ពុជា។

របាយការណ៍នេះ នឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់ទាំងឡាយណាដែលចាប់អារម្មណ៍ចំពោះការស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា រួមមានទាំងអ្នកនយោបាយ អ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវ អ្នកផ្សព្វផ្សាយ គ្រូបង្រៀន និស្សិត និងអាចទាំងកសិករទៀតផង។ សម្រាប់វិទ្យាស្ថានផ្ទាល់ របាយការណ៍នេះជាការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំនិងមន្ត្រីរបស់ខ្លួនឲ្យបន្តខិតខំស្រាវជ្រាវដើម្បីសម្រេចនូវបេសកកម្មក្នុងកិច្ចការស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាកសិកម្មនៅកម្ពុជា។

ខ្ញុំសង្ឃឹមថា របាយការណ៍នេះជាប្រភពព័ត៌មានដ៏មានសារៈសំខាន់សម្រាប់អ្នកប្រើប្រាស់។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦

បណ្ឌិត អ៊ុក ម៉ាការា
នាយកវិទ្យាស្ថាន

Cambodian Agricultural Research and Development Institute (CARDI)

# មាតិកា


| | ទំព័រ |
|---|---|
| អារម្ភកថា ........................................ | I |
| មាតិកា ........................................ | II |
| ១. សេចក្តីផ្តើម ........................................ | 1 |
| ២. សមិទ្ធផលរួមឆ្លើយតបទៅនឹងសូចនាករក្នុងការអនុវត្តន៍ឆ្នាំ២០១៤-២០១៥ .................... | 2 |
| ៣. សមិទ្ធផលនៃការស្រាវជ្រាវ អភិវឌ្ឍន៍បច្ចេកវិទ្យា និងផ្សព្វផ្សាយក្នុងឆ្នាំ២០១៥.................... | 2 |
| ៣.១. អនុកម្មវិធី១.១៨៖ ស្រាវជ្រាវដើម្បីបង្កើនផលិតភាពកសិកម្ម .................... | 3 |
| ១. ការអភិរក្សពូជដំណាំ ........................................ | 3 |
| ២. ការបញ្ចេញពូជដំណាំថ្មីៗ ........................................ | 3 |
| ៣. ថ្នាំពុលកម្ចាត់មមាចត្នោត ........................................ | 3 |
| ៤. ឧបករណ៍ដាំបង្កប់គ្រាប់ពូជស្រូវ ........................................ | 4 |
| ៥. ការប្រើប្រាស់គ្រឿងយន្តក្នុងដំណាំស្រូវ ........................................ | 4 |
| ៦. ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជីវភាពកសិករ .................... | 4 |
| ៧. ឥទ្ធិពលនៃការដាំដុះដំឡូងមីលើគុណភាពដី ........................................ | 5 |
| ៨. ការបាត់បង់ក្រោយពេលប្រមូលផលរបស់បន្លែស្ពៃតឿ ........................................ | 5 |
| ៣.២. អនុកម្មវិធីទី ១.១៩៖ ស្រាវជ្រាវដើម្បីលើកកម្ពស់ពិពិធកម្មដំណាំកសិកម្មនិងការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម .................... | 6 |
| ៩. ផលិតកម្មគ្រាប់ពូជស្រូវ ........................................ | 6 |
| ១០. បង្ហំបច្ចេកទេសបង្កើនផលិតភាពស្រូវវស្សានៅតំបន់ឆ្នេរ.................... | 6 |
| ១១. ការដាំដុះពូជស្រូវដែលបញ្ចេញដោយវិទ្យាស្ថានកាឌី .................... | 7 |
| ១២. ការផ្សព្វផ្សាយបច្ចេកទេស ........................................ | 7 |
| ១៣. អាហារូបត្ថម្ភរបស់អង្ករសពូជស្រូវផ្ការំដួល .................... | 7 |
| ៣.៣. អនុកម្មវិធីទី ១.២០៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍធនធានមនុស្សផ្នែកពិសោធន៍ស្រាវជ្រាវ .................... | 8 |
| ១៤. ការពង្រឹងនិងអភិវឌ្ឍធនធានមនុស្ស ........................................ | 8 |
| ១៥. អត្ថបទវិទ្យាសាស្ត្រ ........................................ | 8 |
| ១៦. ការបោះពុម្ពនិងផ្សព្វផ្សាយ ........................................ | 9 |
| ១៧. គេហទំព័រវិទ្យាស្ថាន ........................................ | 9 |
| ៤. សន្និដ្ឋាននិងសំណូមពរ ........................................ | 10 |
| ៥. ទិសដៅយុទ្ធសាស្ត្រ ........................................ | 10 |


Cambodian Agricultural Research and Development Institute(CARDI)

# ១. សេចក្តីផ្តើម

ក្នុងបរិបទនៃការលើកស្ទួយវិស័យកសិកម្ម រាជរដ្ឋាភិបាលអាណត្តិទី៥ បានផ្តោតលើគោលដៅជាយុទ្ធសាស្រ្ត៤ ជាសំខាន់រួមមាន៖ (១) ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម (២) ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម (៣) កំណែទម្រង់ដីធ្លី ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (៤) ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព តាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាតាមអភិក្រម និងក្នុងវិសាលភាពនិងល្បឿនថ្មី ដើម្បីប្រែក្លាយវិស័យនេះពីដំណាក់កាលនៃការអភិវឌ្ឍន៍តាមបែបវិបុលកម្ម (បើកទូលាយ) ពោលគឺពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់ (ធនធានដីនិងធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ឈានទៅរកដំណាក់កាលថ្មី ដែលផ្តោតលើផលិតកម្មតាមបែបប្រពលវប្បកម្ម (ស៊ីជម្រៅ) ពោលគឺពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី ការស្រាវជ្រាវ និងការអភិវឌ្ឍន៍យន្តូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មមុខដំណាំ និងផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វនិងវារីវប្បកម្មផង ដោយគិតគូរផងដែរអំពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព និងការធានាចីរភាព បរិស្ថាននិងធនធានធម្មជាតិ។

ឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងនូវផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤–២០១៨ និងដាក់ចុះនូវទិសដៅគោលនយោបាយរួមសំដៅ **ជំរុញកំណើនក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម និងការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព** តាមរយៈការអនុវត្តន៍នូវកម្មវិធីចំនួន៥ គឺ (១) បង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម (២) ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ (៣) ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព (៤) ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព (៥) ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស។

ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទបានប្រគល់ភារកិច្ចឲ្យវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (វិទ្យាស្ថានកាឌី) ចូលរួមក្នុងកម្មវិធីទី១៖ បង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ក្នុងគោលបំណងជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម សំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីប្រកបដោយនិរន្តរភាព។ កម្មវិធីទី១នេះ មានអនុកម្មវិធីសរុបចំនួន២០ ដែលក្នុងនោះ វិទ្យាស្ថានកាឌីត្រូវអនុវត្តនូវអនុកម្មវិធីចំនួន៣ គឺ (១) អនុកម្មវិធីទី១.១៨៖ ស្រាវជ្រាវដើម្បីលើកកម្ពស់ផលិតតាពដំណាំកសិកម្ម (២) អនុកម្មវិធីទី១.១៩៖ ស្រាវជ្រាវដើម្បីលើកកម្ពស់ពិពិធកម្មដំណាំកសិកម្មនិងការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម និង (៣) អនុកម្មវិធីទី១.២០៖ បង្កើនប្រសិទ្ធតាពសេវាគាំទ្រនិងអភិវឌ្ឍធនធានមនុស្សផ្នែកពិសោធន៍ស្រាវជ្រាវ។

របាយការណ៍នេះ គឺជាសេចក្តីសង្ខេបលទ្ធផលសំខាន់ៗឆ្លើយតបទៅនឹងសូចនាករដែលបានព្យាករណ៍ទុកសម្រាប់វិទ្យាស្ថានកាឌីអនុវត្តក្នុងឆ្នាំ២០១៥ នៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤–២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

Cambodian Agricultural Research and Development Institute (CARDI)

## ២. សមិទ្ធផលរួមឆ្លើយតបទៅនឹងសូចនាករក្នុងការអនុវត្តន៍ឆ្នាំ២០១៤ និង ២០១៥

ក្នុងរយៈពេល២ឆ្នាំនៃការអនុវត្តន៍នូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤–២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាអាណាព្យាបាលផ្នែកបច្ចេកទេស និងការគាំទ្ររបស់ក្រសួងសេដ្ឋកិច្ចដែលជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ព្រមទាំងក្រោមការដឹកនាំតម្រង់ទិសរបស់ក្រុមប្រឹក្សាភិបាល រួមទាំងកិច្ចសហការពីអង្គភាពជំនាញនិងមន្ទីរកសិកម្មទាំងអស់ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពស្រាវជ្រាវអន្តរជាតិនានា និងអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសប្រជាកសិករកម្ពុជា វិទ្យាស្ថានកាឌីសម្រេចបាននូវលទ្ធផលគួរជាទីមោទន ស្របទៅតាមសូចនាករដែលបានព្យាករណ៍ទុក ដូចមានបង្ហាញក្នុងតារាង១។

តារាង១. លទ្ធផលឆ្លើយតបទៅនឹងសូចនាករដែលបានព្យាករណ៍ក្នុងនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤–២០១៨

| សូចនាករលទ្ធផល | ឯកតា | ឆ្នាំ២០១៤ | | ឆ្នាំ២០១៥ | | ព្យាករណ៍តាមឆ្នាំ | | |
|---|---|---|---|---|---|---|---|---|
| | | ព្យាករណ៍ | អនុវត្តបាន | ព្យាករណ៍ | អនុវត្តបាន | ២០១៦ | ២០១៧ | ២០១៨ |
| អនុកម្មវិធីទី១.១៨. ស្រាវជ្រាវដើម្បីបង្កើនផលិតភាពដំណាំកសិកម្ម | | | | | | | | |
| ១. ចំនួនពូជដំណាំដែលត្រូវបានប្រមូលបន្ថែម | សំណាក | ១០០ | ៣៩១ | ១០០ | ៣២៤ | ១០០ | ១០០ | ១០០ |
| ២. ប្រភេទពូជដំណាំថ្មីៗដែលត្រូវបានបញ្ចេញ | ពូជ | ២ | ០ | ១ | ៤ | ២ | ១ | ៣ |
| ៣. បច្ចេកទេសថ្មីៗដែលត្រូវបានបង្កើត | ចំនួន | ៧ | ៨ | ៦ | ៦ | ៧ | ១០ | ៩ |
| អនុកម្មវិធីទី១.១៩.ការស្រាវជ្រាវដើម្បីលើកកម្ពស់ពិពិធកម្មដំណាំកសិកម្មនិងការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម | | | | | | | | |
| ១. បង្ហុំបច្ចេកវិទ្យាពិពិធកម្មដំណាំស្រូវជាមូលដ្ឋានត្រូវបានបញ្ចេញ | ចំនួន | ២ | ១ | ១ | ១ | ១ | ១ | ១ |
| ២. កំណើនផ្ទៃដីដាំដុះដោយពូជស្រូវនិងបច្ចេកទេសថ្មីៗដែលបញ្ចេញដោយកាឌី | % | ២ | ២ | ២ | ២ | ២ | ២ | ២ |
| ៣. បរិមាណគ្រាប់ពូជដំណាំដែលមានភាពសុទ្ធខ្ពស់និងគុណភាពល្អ | តោន | ៥០ | ១០២ | ៥៥ | ៧៨ | ៥៥ | ៦០ | ៦០ |
| អនុកម្មវិធីទី១.២០.បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍធនធានមនុស្សផ្នែកពិសោធន៍ស្រាវជ្រាវ | | | | | | | | |
| ១. មន្ត្រីបញ្ចប់ការសិក្សាថ្នាក់ក្រោយឧត្តមនិងឱកាសសិក្ខាកាមទទួលបានការបណ្តុះបណ្តាល | ឱកាស | ១០៥ | ៧៨១ | ១០៥ | ៦៨៦ | ១០៥ | ១០៥ | ១០៥ |
| ២. ឯកសារវិទ្យាសាស្ត្របោះពុម្ពផ្សាយ | ប្រភេទ | ២ | ១៤ | ៣ | ៩ | ៥ | ៦ | ៧ |
| ៣. កំណើនប្រសិទ្ធភាពនៃប្រព័ន្ធទ្រទ្រង់ក្នុងការផ្តល់សេវាស្រាវជ្រាវដល់សេដ្ឋកិច្ច | % | ២ | ២ | ២ | ២ | ៥៥ | ៦០ | ៦០ |

Cambodian Agricultural Research and Development Institute (CARDI)

## ៣. សមិទ្ធផលនៃការស្រាវជ្រាវ អភិវឌ្ឍន៍បច្ចេកវិទ្យា និងផ្សព្វផ្សាយក្នុងឆ្នាំ២០១៥

អនុវត្តតាមតួនាទីនិងភារកិច្ចរបស់ខ្លួន ជាពិសេសដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤–២០១៨ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទក្នុងការសម្រេចឲ្យបាននូវគោលនយោបាយចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ២០១៥នេះ វិទ្យាស្ថានកាឌីបានបន្តការខិតខំប្រឹងប្រែងអនុវត្តយ៉ាងសស្រាក់សស្រាំលើការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាលើ (១)ការអភិវឌ្ឍន៍ពូជដំណាំផ្សេងៗ រួមមានស្រូវ ពោត

សណ្តែក ដំឡូងមី បន្លែ ឈើហូបផ្លែ ដំណាំលម្អ (២)ការគ្រប់គ្រងដីជាតិដីនិងសារធាតុចិញ្ចឹម (៣)ការអភិវឌ្ឍន៍បច្ចេកទេសដាំដុះនិងប្រព័ន្ធកសិកម្ម (៤)កិច្ចការពារដំណាំពីការបំផ្លាញរបស់កត្តាចង្រៃផ្សេងៗ (៥)ការអភិវឌ្ឍន៍បច្ចេកទេសមុននិងក្រោយពេលប្រមូលផល (៦)ការវិភាគសេដ្ឋកិច្ចសង្គមពាក់ព័ន្ធវិស័យកសិកម្ម និង(៧)ការបណ្តុះបណ្តាល ការផ្សព្វផ្សាយចំណេះដឹងបច្ចេកទេសនិងព័ត៌មានកសិកម្ម។ ជារួម បានធ្វើពិសោធន៍ចំនួន១១០ប្រភេទ នៅ៧១០កន្លែង ការអង្កេត ទិវាស្រែបង្ហាញ និងបណ្តុះបណ្តាល ដោយទទួលបានលទ្ធផលទៅតាមគោលបំណងនិងសូចនាករក្នុងអនុកម្មវិធីទាំង៣ តាមលំដាប់លំដោយដូចខាងក្រោម។

## ៣.១. អនុកម្មវិធីទី១.១៨៖ ស្រាវជ្រាវដើម្បីបង្កើនផលិតភាពកសិកម្ម

អនុកម្មវិធីនេះ មានគោលបំណង ជំរុញការស្រាវជ្រាវបច្ចេកវិទ្យានិងការបញ្ចេញប្រភេទពូជដំណាំអតិផលដែលធន់នឹងកត្តាជីវៈនិងកត្តាអជីវៈ ដើម្បីធានានិរន្តរភាពប្រភពធនធានពន្ធុរុក្ខជាតិសម្រាប់ស្បៀងនិងកសិកម្ម និងទទួលបាននូវលទ្ធផលធំៗចំនួន៩ចំណុចដូចខាងក្រោម៖

១. **ការអភិរក្សពូជដំណាំ:** បានចុះកិច្ចព្រមព្រៀងអភិរក្សពូជដំណាំរយៈពេលយូរនៅរដ្ឋបាលអភិវឌ្ឍន៍ជនបទកូរ៉េនិងបានយកពូជស្រូវចំនួន២១៧បញ្ជីកទៅរក្សាទុករយៈពេលយូរនៅធនាគាពន្ធុប្រទេសកូរ៉េ។ ទន្ទឹមនឹងនេះ ពូជដំណាំថ្មីៗទៀតចំនួន៣២៤សំណាកត្រូវបានប្រមូលទុក ដោយក្នុងនោះ ពូជស្រូវចំនួន៦៧សំណាក ព្រមទាំងពូជត្រសក់ស្រូវ និងម្ទេសផិត១០០សំណាកបានដាំវាយតម្លៃ។ គិតជារួមត្រឹមដំណាច់ឆ្នាំ២០១៥នេះ ពូជដំណាំសរុបចំនួន៣៣ប្រភេទ ដែលរួមមានស្រូវចំនួន៦.៦៤៥បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន៣២ប្រភេទរួមមាន១.២៥៥បញ្ជីក/សំណាក ដែលសរុបទាំងអស់មានចំនួន៧.៩០០បញ្ជីក/សំណាកបានអភិរក្សនៅក្នុងធនាគារពន្ធុរបស់វិទ្យាស្ថានកាឌី សម្រាប់ប្រើប្រាស់ក្នុងកិច្ចអភិវឌ្ឍន៍ពូជដំណាំក្នុងរយៈពេលយូរអង្វែង។

២. **ការបញ្ចេញពូជដំណាំថ្មីៗ:** ក្រៅពីពូជស្រូវ ផ្ការំដួលប្រាំង និង ខា១៤ ព្រមទាំងពូជពោតដំណើប ស៊ីអឹម១ ដែលបានបញ្ចេញនាដើមឆ្នាំ២០១៥ ដែលបានបង្ហាញក្នុងរបាយការណ៍សង្ខេបស្តីពីសមិទ្ធផលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាផលិតផលដំណាំឆ្នាំ២០១៤-២០១៥ និងទិសដៅឆ្នាំ២០១៥-២០១៦ វិទ្យាស្ថានកាឌីក៏បានបញ្ចេញពូជស្រូវថ្មីមួយទៀតឈ្មោះ ខា១៥ ដែលជាពូជស្រូវស្រាលមិនប្រកាន់រដូវ មានប្រភពដើមពីអ៊ីរី (IR04N155)។ ពូជនេះជាមធ្យមមានអាយុកាល១០០ថ្ងៃ កម្ពស់១,០ម៉ែត្រ ប្រវែងគ្រាប់អង្ករ៧,០មីលីម៉ែត្រ បន្ទារគ្រាប់២,១មីលីម៉ែត្រ មានកម្រិតអាមីឡូស២១,៦% និងទិន្នផលមធ្យមទាំងរដូវប្រាំងនិងវស្សា៤,០តោន/ហិកតា ព្រមទាំងធន់ទ្រាំមធ្យមទៅនឹងមមាចត្នោត។ ពូជស្រូវខា១៥ អាចផ្តល់ផលរហូតដល់៧,៤តោន/ហិកតា។ ជាសរុប ក្នុងឆ្នាំ២០១៥នេះ វិទ្យាស្ថានកាឌីបានបញ្ចេញពូជដំណាំថ្មីៗចំនួន៤ពូជបន្ថែមទៀត។

៣. **ថ្នាំពុលកម្ចាត់មមាចត្នោត:** តាមលទ្ធផលពិសោធន៍ថ្នាំពុលកសិកម្ម៤ប្រភេទ (តារាង២) បានបង្ហាញថា ថ្នាំ APATA មានប្រសិទ្ធភាពខ្ពស់ជាងគេក្នុងការកម្ចាត់ទាំងមេមមាច (៩៣%) និងទាំងជួយកាត់បន្ថយអត្រាពងញាស់បានច្រើនប្រហាក់ប្រហែលនឹងការប្រើថ្នាំ Dinotefuran ដែរ (ក្រាហ្វិក១)។ ការប្រើប្រាស់ថ្នាំនេះ ត្រូវផ្លាស់ប្តូរជាមួយថ្នាំ OSHIN20WP ម្តងម្កាលផងដែរ ដើម្បីរក្សាប្រសិទ្ធភាពនៃថ្នាំ និងជួយកាត់បន្ថយភាពធន់របស់សត្វល្អិតទៅលើថ្នាំ។

តារាង២. ឈ្មោះថ្នាំពុលកសិកម្ម កម្រិតធាតុសកម្ម និងបរិមាណប្រើប្រាស់

| ឈ្មោះពាណិជ្ជកម្ម | ឈ្មោះសារធាតុសកម្ម | កម្រិតធាតុសកម្ម(%) | បរិមាណធាតុសកម្មប្រើប្រាស់ (ក្រ/ហាត) | បរិមាណថ្នាំប្រើប្រាស់ (ក្រ/ហាត) |
|---|---|---|---|---|
| Control | | | | |
| Takumi 20 WG | Flubendiamide | ២០ | ១៦ | ៨០ |
| Chess 50 WG | Pymetrozine | ៥០ | ១២០ | ២៤០ |
| APATA | Fipronil/Imidaclopride | ៤០ | ១២០ | ៣០០ |
| OSHIN 20 WP | Dinotefuran | ២០ | ២៦ | ១៣០ |

Cambodian Agricultural Research and Development Institute (CARDI)

ក្រាហ្វិក១. ប្រសិទ្ធភាពរបស់ថ្នាំកសិកម្មដែលមានលក់នៅលើទីផ្សារទៅលើមមាចនិងពងញាស់ (LSD5% អត្រាមមាចងាប់=៨ និងអត្រាពងញាស់=៥)




៤. ឧបករណ៍ដាំបង្កប់គ្រាប់ពូជស្រូវ: ឧបករណ៍នេះត្រូវបានកែច្នៃឲ្យបានសមស្របតាមលក្ខខណ្ឌប្រទេសកម្ពុជា ហើយលទ្ធផលដែលទទួលបានពីការសាកល្បងរបស់កសិករចំនួន២៣នាក់ បានបង្ហាញថា ទិន្នផលស្រូវដាំដោយឧបករណ៍នេះជាមធ្យមមាន៣,២៥ត/ហត ដែលខ្ពស់ជាងការព្រោះដោយដៃប្រមាណ០,៤៥ត/ហត។ ក្រៅពីផ្តល់ទិន្នផលខ្ពស់ដោយសារស្រូវដុះលូតលាស់បានល្អ និងស្មើគ្នាជាជួរស្រួលដើរថែទាំ ឧបករណ៍នេះ ក៏ជួយកាត់បន្ថយបរិមាណគ្រាប់ពូជពី១២០–១៥០គក្រ/ហត មក៦០–៨០គក្រ/ហតផងដែរ។

៥. ការប្រើប្រាស់គ្រឿងយន្តក្នុងដំណាំស្រូវ: លទ្ធផលសម្ភាសន៍ជាមួយកសិករក្នុងខេត្តចំនួន៨ បានបង្ហាញថា ក្នុងការរៀបចំដីស្រែ មានកសិករប្រមាណ១៧%នៅប្រើប្រាស់គោក្របី ៦១%ប្រើប្រាស់គោយន្ត និង២២%ប្រើប្រាស់ត្រាក់ទ័រ (ក្រាហ្វិក២)។ មូលហេតុសំខាន់របស់កសិករដែលនៅប្រើប្រាស់គោក្របីគឺ ក. អត់មានលទ្ធភាពទិញឬជួល (៣១%) ខ. ដីស្រែមានទំហំតូចពេក (២១%) គ. ចង់បានជីលាមកសត្វដាក់ដំណាំ (១៣%) និង ឃ. ផ្សេងៗទៀត (៣៦%) (ក្រាហ្វិក២)។ ដោយឡែកចំពោះការច្រូតកាត់វិញ មានកសិករដែលច្រូតកាត់ដោយដៃក្នុងស្រែប្រាំងប្រមាណ១០% ស្រែដើមរដូវវស្សាប្រមាណ១៩% និងស្រែវស្សាប្រមាណ៤២% (ក្រាហ្វិក៣)។ កសិករដែលប្រើម៉ាស៊ីនច្រូតផ្តួលដើមក្នុងស្រែដើមរដូវវស្សាមានច្រើនជាងគេ (១៦%) ស្រែប្រាំង (១១%) និងស្រែវស្សាតិចជាងគេ (៧%)។ ម៉ាស៊ីនច្រូតកាត់ដោយម៉ាស៊ីនកុំបៃមានការពេញនិយមខ្លាំង គឺរហូតដល់៨០%ចំពោះស្រែប្រាំង ៦៤%ចំពោះស្រែដើមរដូវវស្សា និង៥១%ចំពោះស្រូវវស្សា។ តម្លៃឈ្នួលច្រូតកាត់ដោយម៉ាស៊ីនកុំបៃ ប្រែប្រួលពី២សែនរៀលទៅដល់៦សែនរៀល/ហិកតា ទៅតាមស្ថានភាពស្រូវ និងជាមធ្យមសម្រាប់ស្រូវប្រាំងនិងដើមរដូវវស្សាគឺ២,៥សែនរៀល និងស្រូវវស្សាគឺ៣,៥សែនរៀល/ហិកតា។

Cambodian Agricultural Research and Development Institute (CARDI)







ក្រាហ្វិក២. ការប្រើប្រាស់មធ្យោបាយរៀបចំដីស្រែ (%) ក្រាហ្វិក៣. ការប្រើប្រាស់មធ្យោបាយប្រមូលផលស្រូវ (%)

៦. ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជីវភាពកសិករ: លទ្ធផលនៃការសិក្សាជាមួយកសិករចំនួន១៥០នាក់ ដែលដាំដុះដំណាំស្រូវវស្សានៅខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តកំពង់ចាម បានបង្ហាញថា មានកសិករប្រមាណជា៨៣% បានកត់សម្គាល់ឃើញថា មានការប្រែប្រួលអាកាសធាតុក្នុងកំឡុងពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ។ ការប្រែប្រួលអាកាសធាតុបានបង្កឲ្យមានការកើនឡើងនូវសីតុណ្ហភាព រដូវប្រាំងមានរយៈពេលវែង រដូវវស្សាមានរយៈពេលខ្លី បរិមាណទឹកភ្លៀងទាប ភ្លៀងមិនធ្លាក់ដូចការគិតទុក (ភ្លៀងធ្លាក់មុនរដូវកាល ភ្លៀងធ្លាក់យឺតជាងរដូវកាល) ខ្យល់ខ្លាំង (ព្យុះ) រន្ទះ និងសីតុណ្ហភាពធ្លាក់ចុះទាបខុសប្រក្រតី។ កសិករនៅក្នុងខេត្តទាំង៣ បានបញ្ជាក់ថាអាកាសធាតុប្រែប្រួល

ធ្វើឲ្យមានការផ្លាស់ប្តូរនូវមុខងារនិងរយៈពេលនៃការដាំដំណាំ ការទុកដីទំនេរចោល (មិនដាំដំណាំ) ការកើតសត្វល្អិត និងជំងឺ ការបាត់បង់ជីជាតិដី និងទិន្នផលដំណាំធ្លាក់ចុះគួរឲ្យកត់សម្គាល់។ ក្រៅពីផលប៉ះពាល់ទៅលើដំណាំ មនុស្ស និងជីវភាពប្រចាំថ្ងៃរបស់ប្រជាកសិករក៏បានរងការប៉ះពាល់ផងដែរ ដែលជារួមមាន ការកើនឡើងនូវអំពើហឹង្សា ការខ្វះខាតក្នុងការផ្គត់ផ្គង់អាហារ បញ្ហាសុខភាព ការកើនឡើងនូវភាពតានតឹង និងកង្វល់គ្រួសារ។

**៧. ឥទ្ធិពលនៃការដាំដុះដំឡូងមីលើគុណភាពដី:** លទ្ធផលនៃការសិក្សានៅបីទីតាំងពិសោធន៍បានបង្ហាញថាដំឡូងមី បានផ្តល់ទិន្នផលមើមស្រស់ជាមធ្យម២៧ត/ហត ចំពោះការមិនដាក់ជី និងពី៣១–៣៣ត/ហត ចំពោះការដាក់ជី NPK តាមកម្រិតផ្សេងៗគ្នា (តារាង៣)។ ចំណែកកម្រិតជាតិម្សៅមានពី២៧–២៩% ដោយមិនមានភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងបច្ច័យជីឡើយ។ ក្រោយពេលដាំដំឡូងមីយើងសង្កេតឃើញថា តម្លៃ pH ដី មានកំណើនប្រហែល០,២ឯកតា តម្លៃកាបោនសរីរាង្គ (C) មានកំណើនប្រមាណ០,២៧– ០,៦២% និងផូស្វ័រ (P) មានកំណើនប្រហែល ១,៨៦–៤,៣៤មក្រ/គក្រ បើធៀបនឹងតម្លៃមុនពេលដាំ។ ចំពោះតម្លៃអាសូតសរុប (N) និងប៉ូតាស្យូម (K) ហាក់ដូចជាពុំមានការប្រែប្រួលគួរឲ្យកត់សម្គាល់នៅឡើយសម្រាប់ការដាំដុះដំឡូងមីក្នុងឆ្នាំទី១។

តារាង៣. ឥទ្ធិពលនៃការដាំដុះដំឡូងមីក្នុងឆ្នាំទី១ទៅលើគុណភាពដី

| បច្ច័យពិសោធន៍* | វាយនភាពដី (Soil texture) | pH ដី | កាបោនសរីរាង្គ (Organic C) (%) | អាសូតសរុប (Total N) % | ផូស្វ័រ (available P) (mg/kg) | ប៉ូតាស្យូម (exch. K) (cmol/kg) | ទិន្នផលមើមស្រស់ (t/ha) | កម្រិតជាតិម្សៅ (%) |
|---|---|---|---|---|---|---|---|---|
| **មុនធ្វើពិសោធន៍** | ឥដ្ឋល្បាប់ | 8.07 | 0.94 | 0.12 | 3.43 | 0.48 | - | - |
| **ក្រោយធ្វើពិសោធន៍** | | | | | | | | |
| T0. មិនដាក់ជី | ឥដ្ឋល្បាប់ | 8.30 | 1.21 | 0.11 | 5.29 | 0.48 | 26.93 | 28 |
| T1. NPK កម្រិតទាប | ឥដ្ឋល្បាប់ | 8.27 | 1.56 | 0.10 | 7.01 | 0.50 | 31.93 | 29 |
| T2. NPK កម្រិតមធ្យម | ឥដ្ឋល្បាប់ | 8.29 | 1.31 | 0.10 | 7.32 | 0.51 | 31.02 | 28 |
| T3. NPK កម្រិតខ្ពស់ | ឥដ្ឋល្បាប់ | 8.27 | 1.50 | 0.11 | 7.77 | 0.43 | 32.94 | 27 |

* កម្រិតជី NPK (kg/ha): T1: 40-20-80, T2: 80-40-80, T3: 160-80-100 គិតជា N, $P_2O_5$, $K_2O$

**៨. ការបាត់បង់ក្រោយពេលប្រមូលផលរបស់បន្លែស្ពៃក្តោប/ស្ពៃតឿ:** លទ្ធផលនៃការសិក្សាបានបង្ហាញថា ស្ពៃតឿដែលកសិករដាំនៅស្រុកស្អាងនិងដឹកមកលក់ឲ្យអ្នកប្រមូលទិញក្នុងស្រុក ហើយអ្នកប្រមូលទិញក្នុងស្រុកយកមកលក់បន្តឲ្យអ្នកប្រមូលទិញនៅផ្សារនាគមាស និងជាចុងក្រោយបន្តដឹកយកទៅលក់ដល់ទីផ្សារខេត្តសៀមរាប ត្រូវបានរលួយខូចអស់ប្រមាណ៣០% និងស្រកទម្ងន់អស់២,៥%។

ជារួម លទ្ធផលក្នុងអនុកម្មវិធីទី១.១៨ ដែលសម្រេចបានក្នុងឆ្នាំ២០១៥នេះ គឺបានល្អប្រសើរ ដោយក្នុងនោះ ចំនួនពូជដំណាំដែលប្រមូលបានមានរហូតដល់៣២៤សំណាក ដែលលើសពីការព្យាករណ៍ចំនួន២២៤សំណាក ពូជដំណាំដែលបានបញ្ចេញពូជស្រូវចំនួន៣ និងពូជពោតដំណើបចំនួន១ ដែលលើសពីការព្យាករណ៍ចំនួន៣ពូជ ហើយបច្ចេកទេសថ្មីគឺបានស្មើទៅនឹងការព្យាករណ៍ដែលមានចំនួន៦ (តារាង៤)។

តារាង៤. លទ្ធផលឆ្លើយតបទៅនឹងសូចនាករក្នុងអនុកម្មវិធី១.១៨៖ស្រាវជ្រាវដើម្បីបង្កើនផលិតភាពដំណាំកសិកម្ម

| សូចនាករលទ្ធផល | ឯកតា | ត្រឹមឆ្នាំ២០១៤ | ក.ផែនការ២០១៥ | ខ.អនុវត្តបាន២០១៥ | ខ/ក (%) |
|---|---|---|---|---|---|
| ១. ចំនួនពូជដំណាំដែលត្រូវបានប្រមូលបន្ថែម | សំណាក | ៧.៥៧៦ | ១០០ | ៣២៤ | ៣២៤ |
| ២. ប្រភេទពូជដំណាំថ្មីៗដែលត្រូវបានបញ្ចេញ | ពូជ | ៥១ | ១ | ៤ | ៤០០ |
| ៣. បច្ចេកទេសថ្មីៗដែលត្រូវបានបង្កើត | ចំនួន | ៤០ | ៦ | ៦ | ១០០ |

Cambodian Agricultural Research and Development Institute(CARDI)

### ៣.២. អនុកម្មវិធីទី ១.១៩៖ ស្រាវជ្រាវដើម្បីលើកកម្ពស់ពិពិធកម្មដំណាំកសិកម្មនិងការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម

គោលបំណងរបស់អនុកម្មវិធីទី១.១៩ គឺអភិវឌ្ឍនិងផ្ទេរបង្កុំបច្ចេកទេសដាំដុះដំណាំសមស្របតាមលក្ខខណ្ឌដាំដុះនិងសង្គម-សេដ្ឋកិច្ចរបស់កសិករ សំដៅរក្សានិរន្តរភាពកំណើនផលិតកម្មដំណាំនិងសុវត្ថិភាព ដោយទទួលបាននូវលទ្ធផលសម្រេចចំនួន៥ដូចខាងក្រោម៖

៩. ផលិតកម្មគ្រាប់ពូជស្រូវ: រាល់ពូជដំណាំដែលវិទ្យាស្ថានបានបញ្ចេញជូនកសិករប្រើប្រាស់ត្រូវបានធានានូវភាពសុទ្ធរបស់វា តាមរយៈការផលិតគ្រាប់ពូជសុទ្ធគ្រឹះ (Foundation seed) ផ្គត់ផ្គង់តាមការបញ្ជាទិញរបស់ក្រុមហ៊ុនឯកជន សហគមន៍កសិកម្ម និងគម្រោងអភិវឌ្ឍន៍នានាដែលអនុវត្តដោយអង្គភាពជំនាញរបស់ក្រសួង និងអង្គការផ្សេងៗដើម្បីផលិតនិងផ្គត់ផ្គង់បន្តជូនកសិករ។ ក្នុងឆ្នាំ២០១៥ គ្រាប់ពូជស្រូវប្រមាណ៧៨តោនបានផលិត ដោយក្នុងនោះប្រមាណ៣៧តោនផលិតដោយវិទ្យាស្ថានកាឌី និងជាង៤១តោនផលិតដោយកសិករសហការតាមរយៈការបញ្ជ្រាបបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវវស្សា។ នាឱកាសទស្សនាពិពណ៌របស់ក្រសួងក្នុងទិវាស្រូវ–អង្ករ រៀបចំដោយសហព័ន្ធស្រូវ–អង្ករកម្ពុជា ដែលប្រារព្ធនៅអូតែលសុខានាថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៥ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានបញ្ជាក់ថា ដើម្បីធានានូវភាពសុទ្ធរបស់ពូជស្រូវដែលក្រសួងបានបញ្ចេញ វិទ្យាស្ថានកាឌីត្រូវតែបន្តផលិតគ្រាប់ពូជសុទ្ធគ្រឹះផ្គត់ផ្គង់ជូនអតិថិជនឲ្យផលិតគ្រាប់ពូជចំណាត់ថ្នាក់បន្តបន្ទាប់ទៀតផ្គត់ផ្គង់ជូនកសិករដាំដុះ។ នាឱកាសសន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនេះ វិទ្យាស្ថានកាឌីបានចែកគ្រាប់ពូជស្រូវសុទ្ធគ្រឹះជូនដល់មន្ទីរកសិកម្មទាំង២៥ នូវពូជដំណើបស្បៃមង្គលចំនួន១៥គ.ក្រ/មន្ទីរ និងពូជផ្ការំដួលប្រាំងចំនួន៣០គ.ក្រ/មន្ទីរ ព្រមទាំងនាយកដ្ឋានដំណាំស្រូវ (ដំណើបស្បៃមង្គល=ពូជផ្ការំដួលប្រាំង=៤០គ.ក្រ) ដើម្បីផលិតផ្សព្វផ្សាយជូនកសិករ។

១០. បង្កុំបច្ចេកទេសបង្កើនផលិតភាពស្រូវវស្សានៅតំបន់ឆ្នេរ: យោងតាមលទ្ធផលស្រែបង្ហាញចំនួន៥២កន្លែង (ក្រាហ្វិក៤) ដែលបានអនុវត្តក្នុងរយៈពេល៣ឆ្នាំ (២០១៣ដល់ឆ្នាំ២០១៥) នៅតំបន់ទំនាបឆ្នេរដែលទទួលរងឥទ្ធិពលទឹកប្រៃក្នុងខេត្តព្រះសីហនុ និងកែប បានបង្ហាញថា (១) ពូជស្រូវពូជផ្ការំដួល ផ្ការមៀត និងផ្ការំដេង ដែលជាពូជស្រូវមានគុណភាពល្អនិងមានទីផ្សារ ដុះលូតលាស់បានល្អដោយផ្តល់ផល២,៨៥តោន/ហ.ត ធៀបនឹងពូជស្រូវរបស់កសិករ (២,៦៧តោន/ហ.ត) ធ្វើឲ្យកសិករទទួលបានប្រាក់ដុលចំណេញដុល០,៨៦លានរៀល បន្ថែមទៅលើការប្រើប្រាស់ពូជរបស់កសិករ (០,៧៣លានរៀល) និង(២)ការអនុវត្តន៍តាមបង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវបានបង្កើនទិន្នផលស្រូវរហូតដល់៣,២៥តោន/ហ.ត និងទទួលបានប្រាក់ចំណេញដុលខ្ពស់រហូតដល់១,៩២លានរៀល លើសការប្រើប្រាស់តាមទម្លាប់របស់កសិកររហូតដល់១,១៩លានរៀលក្នុងមួយហិកតា។




ក្រាហ្វិក៤. ទិន្នផលស្រូវមធ្យមឆ្នាំ២០១៥ (តោន/ហ.ត) មធ្យមរយៈពេល៣ឆ្នាំ (២០១៣ - ២០១៥) និងការចំណេញ

Cambodian Agricultural Research and Development Institute (CARDI)

១១. ការដាំដុះពូជស្រូវដែលបញ្ចេញដោយវិទ្យាស្ថានកាឌី: លទ្ធផលនៃការធ្វើអង្កេតជាមួយកសិករ១.៩៦៦គ្រួសារនៅខេត្តចំនួន៨ (តាកែវ ព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ និងកំពង់ចាម) បានបង្ហាញថា ក្នុងរដូវវស្សាឆ្នាំ២០១៤ ផ្ទៃដីស្រែប្រមាណ៥០%បានដាំពូជស្រូវផ្ការំដួល ១០%ពូជស្រូវរាំងជ័យ ៦%ពូជស្រូវបញ្ចេញដទៃទៀត ២៩%ពូជស្រូវប្រពៃណី និង៥%ពូជស្រូវនាំចូលផ្សេងៗទៀត (ក្រាហ្វិក៥)។ ជាសរុប ក្នុងរដូវវស្សាឆ្នាំ២០១៤ កសិករនៅខេត្តទាំង៨ បានដាំដុះពូជស្រូវដែលបញ្ចេញដោយក្រសួងប្រមាណ៦៦%នៃផ្ទៃដី។ តាមរយៈលទ្ធផលនេះ យើងអាចប៉ាន់ប្រមាណបានថា ក្នុងឆ្នាំ២០១៥នេះ យ៉ាងហោចណាស់ ផ្ទៃដីដាំដុះពូជស្រូវរបស់វិទ្យាស្ថានកើនបាន ២%ផងដែរ។

ក្រាហ្វិក៥. ភាគរយផ្ទៃដីដាំដុះពូជស្រូវបញ្ចេញដោយវិទ្យាស្ថានកាឌីក្នុងខេត្តចំនួន៨ នារដូវវស្សាឆ្នាំ២០១៤។




១២- ការផ្សព្វផ្សាយបច្ចេកទេស: បានធ្វើទិវាស្រែបង្ហាញ និងវាយតម្លៃចំនួន១៣កន្លែងនៅខេត្តតាកែវ កែប កំពត កំពង់ចាម ព្រៃវែង ស្វាយរៀង និងសៀមរាប ដែលមានកសិករចូលរួមសរុបចំនួន៩៤២នាក់ និងបានបើកវគ្គបណ្តុះបណ្តាលកសិករចំនួន២៩វគ្គ នៅខេត្តកំពង់ឆ្នាំង កែប ព្រះសីហនុ និងខេត្តរតនៈគីរី ដែលមានកសិករចូលរួមសរុបចំនួន១.០៥០នាក់។ បានចែកគ្រាប់ពូជស្រូវក្នុងចំណោមពូជស្រូវ១០ពូជ ដែលបានកំណត់តាមគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំអង្ករចេញរបស់រាជរដ្ឋាភិបាល ក្នុងមួយគ្រួសារចំនួន៥គីឡូក្រាមជូនដល់កសិករចំនួន១៩៣គ្រួសារដែលក្នុងនោះនៅខេត្តកំពង់ឆ្នាំង រតនៈគីរី និងកែប សរុបចំនួន៩៦៥គ.ក្រ ហើយដែលកសិករផលិតបានប្រមាណ៤១តោនសម្រាប់ទុកជាគ្រាប់ពូជដាំដុះនាឆ្នាំក្រោយបន្តទៀត។

១៣. អាហារូបត្ថម្ភរបស់អង្ករសពូជស្រូវផ្ការំដួល: ដោយលទ្ធផលនៃការវិភាគកាលពីឆ្នាំ២០១០កន្លងមក នៅមានការខ្វះខាតសមាសធាតុអាហារូបត្ថម្ភមួយចំនួន ក្នុងឆ្នាំ២០១៥នេះ វិទ្យាស្ថានកាឌីបានយកអង្ករសរបស់ពូជស្រូវផ្ការំដួលទៅឲ្យមន្ទីរពិសោធន៍ដែលធ្វើការវិភាគលើកមុន ធ្វើការវិភាគបន្ថែមទៀត។ តារាង៤ បង្ហាញនូវលទ្ធផលនៃការវិភាគអាហារូបត្ថម្ភ (Nutrition value) បន្ថែមនៅមន្ទីរពិសោធន៍បរទេសដែលធ្លាប់វិភាគកន្លងមក បំពេញលើការខ្វះខាត (ពណ៌ក្រហម) ចំណែកឯសមាសធាតុអាហារូបត្ថម្ភដទៃទៀត គឺមិនមានភាពខុសគ្នាពីលទ្ធផលក្នុងឆ្នាំ២០១០ឡើយ។

តារាង៤៖ អាហារូបត្ថម្ភមានក្នុងអង្ករសម្រិត (WR) និងអង្ករសម្រូប (BR) របស់ពូជស្រូវផ្ការំដួល

| No | Parameter | Unit | Phka Rumduol | | No | Parameter | Unit | Phka Rumduol | |
|---|---|---|---|---|---|---|---|---|---|
| | | | WR | BR | | | | WR | BR |
| 1 | Fe | mg/kg | 2.35 | 11.20 | 10 | Vitamin A | ppm (mg/kg) | ND | ND |
| 2 | Carbohydrate | g/100g | 79.10 | 75.90 | 11 | Vitamin B2 | ppm (mg/kg) | 0.70 | 2.67 |
| 3 | Dietary fiber | g/100g | 1.99 | 3.82 | 12 | Vitamin B3 | ppm (mg/kg) | 1.60 | 10.16 |
| 4 | Energy | kcal/100g | 356 | 366 | 13 | Vitamin B6 | ppm (mg/kg) | ND | ND |
| 5 | Protein | g/100g | 7.32 | 8.22 | 14 | Vitamin C | ppm (mg/kg) | ND | ND |
| 6 | Total fat | g/100g | 1.16 | 3.29 | 15 | Vitamin D | mcg/kg | ND | 36.00 |
| 7 | Cholesterol | mg/100g | ND | ND | 16 | Vitamin E | ppm (mg/kg) | ND | 5.00 |
| 8 | Polyunsaturated fat | g/100g | 0.40 | 1.03 | 17 | Vitamin K1 | ppm (mg/kg) | ND | ND |
| 9 | Thiamine | ppm (mg/kg) | 0.81 | 2.39 | 18 | Vitamin B12 | mcg/kg | ND | ND |

ND = មិនអាចកំណត់បាន

Cambodian Agricultural Research and Development Institute (CARDI)

លទ្ធផលនៃការអនុវត្តន៍អនុកម្មវិធីទី១.១៩ របស់វិទ្យាស្ថានកាឌី គឺបានឆ្លើយតបទៅនឹងសូចនាករលទ្ធផលដែលបានព្យាករណ៍នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយក្នុងនោះគ្រាប់ពូជស្រូវសុទ្ធល្អនិងមានគុណភាពត្រូវបានផលិតដោយវិទ្យាស្ថានកាឌីផ្ទាល់ចំនួន៣៧តោន និងដោយកសិករសហការចំនួន៤១តោន (តារាង៥)។

តារាង៥. លទ្ធផលឆ្លើយតបទៅនឹងសូចនាករក្នុងអនុកម្មវិធី ១.១៩៖ ស្រាវជ្រាវដើម្បីលើកកម្ពស់ពិពិធកម្មដំណាំកសិកម្មនិងការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម

| សូចនាករលទ្ធផល | ឯកតា | ត្រឹមឆ្នាំ២០១៤ | ក.ផែនការ២០១៥ | ខ.អនុវត្តបាន២០១៥ | ខ/ក (%) |
|---|---|---|---|---|---|
| ១. បង្កំបច្ចេកវិទ្យាពិពិធកម្មដំណាំស្រូវជាមូលដ្ឋានត្រូវបានបញ្ចេញ | ចំនួន | ៣ | ១ | ១ | ១០០ |
| ២. កំណើនផ្ទៃដីដាំដុះដោយពូជស្រូវនិងបច្ចេកទេសថ្មីៗដែលបញ្ចេញដោយកាឌី | % | ៣៤ | ២ | ២ | ១០០ |
| ៣. បរិមាណគ្រាប់ពូជដំណាំដែលមានភាពសុទ្ធខ្ពស់និងគុណភាពល្អ | តោន | ១០២ | ៥៥ | ៧៨ | ១៤២ |

## ៣.៣. អនុកម្មវិធីទី ១.២០. ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍធនធានមនុស្សផ្នែកពិសោធន៍ស្រាវជ្រាវ

អនុកម្មវិធីទី ១.២០ នេះ សំដៅបង្កើនសមត្ថភាពនិងទេពកោសល្យរបស់អ្នកគ្រប់គ្រង អ្នកស្រាវជ្រាវ សេវាទ្រទ្រង់ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ការអភិវឌ្ឍន៍បច្ចេកវិទ្យា ដែលជាសរុបមាន៤ចំណុចធំៗដូចខាងក្រោម៖

១៤. ការពង្រឹងនិងអភិវឌ្ឍធនធានមនុស្ស: បានដឹកនាំនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្មធ្វើការស្រាវជ្រាវនិងសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានចំនួន២៧នាក់។ បានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន១៦លើក ដែលមានអ្នកចូលរួមសរុបចំនួន៦០៤នាក់។ បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន០៨លើក ដែលមានមន្ត្រីវិទ្យាស្ថានទៅចូលរួមសរុបចំនួន១៤នាក់ និងក្រៅប្រទេសចំនួន៤១លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន៥៧នាក់។ មន្ត្រីនិយោជិតសរុបចំនួន៧រូបបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិតនៅក្រៅប្រទេស។

១៥. អត្ថបទវិទ្យាសាស្ត្រ: បានសរសេរនិងចូលរួមសរសេរ ព្រមទាំងបោះពុម្ពអត្ថបទនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិនិងសៀវភៅសន្និសីទនានាបានចំនួន៩អត្ថបទដែលផ្តោតលើប្រធានបទជាភាសាអង់គ្លេសដូចខាងក្រោម៖


1. Birch, C.J., Bonney, L.B., Ives, S. W., McPhee, J. Bounneuang, D., **Seng Vang**, **Sokun Bo** and Sacklokham, S. (2015). Whole of System and Value Chain Analyses reveal research needs in horticulture in Laos and Cambodia. pp72-73 in Book of Abstracts, 'Meeting the Challenge of Productivity in the Tropics, Tropical Agriculture Conference, Brisbane, 16-18 November 2015, Brisbane, Australia.

2. **Chanthy, P.**, R. J. Martin, R. V. Gunning and N. R. Andrew (2015). "Influence of Temperature and Humidity regimes on the Developmental Stages of Green Vegetable Bug, Nezara Viridula (L.) (Hemiptera: Pentatomidae) from Inland and Coastal Populations in Australia." Gen. Appl. Ent 43: 37-55.

3. **Chhourn Orn**, Rieko Shishido, Masahiro Akimoto, Ryo Ishikawa, Than Myint Htun, Ken-Ichi Nonomura, Yohei Koide, Men Sarom, **Seng Vang, Sakhan Sophany**, **Ouk Makara**, and


Cambodian Agricultural Research and Development Institute(CARDI)

Takashige Ishii (2015). Evaluation of genetic variation among wild rice populations in Cambodia. Breeding Science 65: 430–437.

4. Ntui, V. O., **K. Kong**, R. S. Khan, T. Igawa, G. J. Janavi, R. Rabindran, I. Nakamura and M. Mii (2015). "Resistance to Sri Lankan Cassava Mosaic Virus (SLCMV) in Genetically Engineered Cassava cv. KU50 through RNA Silencing." PLoS ONE 10(4): 1-23.
5. Perry L Poulton, Neal P Dalgliesh, **Seng Vang**, **Touch Veasna**, Philip Charlesworth, Alison Laing (2015). Resilience of smallholder farmers in Cambodian lowland rice ecosystems in managing for future climate uncertainty. In: "Building Productive, Diverse and Sustainable Landscapes" - Proceedings of the 17th ASA Conference, 20–24 September 2015, Hobart, Australia. Website: www.agronomy2015.com.au
6. Perry L Poulton, **Touch Veasna**, Neal P Dalgliesh, **Vang Seng** (2015). Applying simulation to improve rice varieties in reducing the on-farm yield gap in Cambodian lowland rice ecosystems. Expl Agric. (2015), volume 51 (2), pp. 264–284.
7. **Seng Vang** and **Hin Sarith** (2015). Land resources of Cambodia: A review of knowledge and management. In: "ISC 2015 - Sustainable Uses of Soil in Harmony with Food Security" – Proceedings of the International Soil Conference, 18-21 August 2015, Cha Am, Thailand.
8. **Seng Vang, Hin Sarith, Touch Veasna, Lim Vanndy, and Ly Tyneth** (2015). Effects on soil qualities and crop yields of applied rice husk biochar fortified with inorganic NPK or organic fertilizers in rice-growing soils of Cambodia. In: "Proceedings of the 2nd National Conference on Agriculture and Rural Development", 21 November 2015, Royal University of Agriculture, Phnom Penh, Cambodia, pp. 1- 4.
9. Vote C., Oeurng C., Sok T., Phongpacith C., Inthavong T., **Seng V**., Eberbach P. and Hornbuckle J. (2015). A comparison of three empirical models for assessing cropping options in a data-sparse environment, with reference to Laos and Cambodia. ACIAR Technical Reports No. 87. Australian Centre for International Agricultural Research: Canberra. 30 pp.

Cambodian Agricultural Research and Development Institute (CARDI)

១៦. ការបោះពុម្ពនិងផ្សព្វផ្សាយ: បានរៀបចំនិងបោះពុម្ពសៀវភៅរបាយការណ៍សរុបចំនួន១.៥៥០ច្បាប់ ព្រឹត្តិប័ត្រព័ត៌មានកសិករសរុបចំនួន១៩.៧០០សន្លឹក និងខិតប័ណ្ណពូជពោត និងប៉េងប៉ោះសរុបចំនួន៧.៥០០សន្លឹក ព្រមទាំងផ្ទាំងបដា (Banner) សរុបចំនួន១០ផ្ទាំង។ បានបែងចែកព្រឹត្តិប័ត្រព័ត៌មានកសិករចំនួន២៦ប្រភេទសរុបចំនួន ១១.៦០០ច្បាប់ ខិតប័ណ្ណពូជពោត និងប៉េងប៉ោះចំនួន៣.៣៣០ច្បាប់ ព្រមទាំងសៀវភៅកម្រងឯកសារក្សេត្របរិស្ថានដំណាំស្រូវក្នុងប្រទេសកម្ពុជា ការកំណត់ក្រុមដីស្រែលក្ខណៈសំខាន់ៗរបស់ពូជស្រូវចំនួន១០ពូជ បង្កុំបច្ចេកទេស ស្មៅចង្រៃនៃដំណាំស្រូវនៅអាស៊ី ដំណាំស្រូវនៅកម្ពុជា សមិទ្ធផលស្រាវជ្រាវ និងសៀវភៅរបាយការណ៍ប្រចាំឆ្នាំរបស់វិទ្យាស្ថានសរុបចំនួន១.៦០០ច្បាប់ ព្រមទាំងផ្ទាំងបដា (Banner) ប្រភេទដី និងប្រភេទក្រុមដីសំខាន់សរុបចំនួន ៣០ផ្ទាំង ជូនថ្នាក់ដឹកនាំក្រសួង ក្រុមប្រឹក្សាភិបាល អង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្ម ការិយាល័យកសិកម្មស្រុក និងអ្នកពាក់ព័ន្ធជាពិសេសដល់កសិករ។

១៧. គេហទំព័រវិទ្យាស្ថាន (Website): ក្នុងរយៈពេលមួយឆ្នាំ២០១៥នេះ មានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មតាមរយៈគេហទំព័ររបស់វិទ្យាស្ថាន http://www.cardi.org.kh សរុបចំនួន៤៣៩.០៩៥នាក់ ដោយគិតជាមធ្យមមានប្រមាណ១.២០៣នាក់/ថ្ងៃ កើនលើសឆ្នាំមុនចំនួន១៤នាក់/ថ្ងៃ។

ជាសរុបសម្រាប់អនុកម្មវិធីទី១.២០ នេះ វិទ្យាស្ថានកាឌីអនុវត្តបានរហូតដល់៥២០%នៃសូចនាករលទ្ធផលទី១ និង ៩០០%នៃសូចនាករលទ្ធផលទី២ ដែលមានបង្ហាញក្នុងតារាង៦។

តារាង៦. លទ្ធផលឆ្លើយតបទៅនឹងសូចនាករក្នុងអនុកម្មវិធី១.២០. ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍធនធានមនុស្សផ្នែកពិសោធន៍ស្រាវជ្រាវដើម្បីពិពិធកម្មនិងផ្សព្វផ្សាយកសិកម្ម

| សូចនាករលទ្ធផល | ឯកតា | ត្រឹមឆ្នាំ២០១៤ | ក.ផែនការ២០១៥ | ខ.អនុវត្តបាន២០១៥ | ខ/ក (%) |
|---|---|---|---|---|---|
| ១. មន្ត្រីបញ្ចប់ការសិក្សាថ្នាក់ក្រោយឧត្តមនិង ឱកាសសិក្ខាកាមទទួលបានការបណ្តុះបណ្តាល | ឱកាស | ៧៨១ | ១៣២ | ៦៨៦ | ៥២០ |
| ២. ឯកសារវិទ្យាសាស្ត្របោះពុម្ពផ្សាយ | ប្រភេទ | ១៤ | ១ | ៩ | ៩០០ |
| ៣. កំណើនប្រសិទ្ធភាពនៃប្រព័ន្ធទ្រទ្រង់ក្នុងការ ផ្តល់សេវាស្រាវជ្រាវដល់សេដ្ឋកិច្ច | % | ១៨ | ២ | ២ | ១០០ |

## ៤. សន្និដ្ឋាននិងសំណូមពរ

ក៏ដូចក្នុងបណ្តាឆ្នាំមុនៗដែរ ក្នុងឆ្នាំ២០១៥នេះ ថ្នាក់ដឹកនាំនិងមន្ត្រីនិយោជិតរបស់វិទ្យាស្ថានកាឌីទាំងអស់ បានបន្តខិតខំប្រឹងប្រែងដឹកនាំនិងបំពេញភារកិច្ច ក្នុងការឆ្លើយតបទៅនឹងបេសកកម្មរបស់ខ្លួន ដែលមានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤–២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល រហូតទទួលបានលទ្ធផលគួរជាទីមោទន ដូចដែលបានបង្ហាញយ៉ាងច្បាស់ខាងលើ។

ក្នុងបរិបទទីផ្សារសេរី ការលើកស្ទួយភាពប្រកួតប្រជែង និងសមាហរណកម្មក្នុងតំបន់ ហើយក៏ដូចទៅនឹងកង្វះខាតកម្លាំងពលកម្មក្នុងវិស័យកសិកម្មផងដែរនោះ និងថ្វីត្បិតតែកន្លងមក វិទ្យាស្ថានកាឌីសម្រេចបាននូវលទ្ធផលយ៉ាងគាប់ប្រសើរ ប៉ុន្តែវិទ្យាស្ថានកាឌីបាននិងកំពុងតែជួបប្រទះនូវ (១) កង្វះមន្ត្រីជំនាញ ដែលទន្ទឹមនឹងគ្នានោះ មន្ត្រីជំនាញដែលទទួលបានការបណ្តុះបណ្តាលមួយចំនួនបានចាកចេញ និងមួយចំនួនទៀតកាន់តែចាស់ (២) យានយន្តបម្រើឲ្យការចុះធ្វើពិសោធន៍និងតាមដាននៅតាមខេត្ត មានសភាពកាន់តែទ្រុឌទ្រោម និង (៣) ការគាំទ្រលើដំណើរការពិសោធន៍ស្រាវជ្រាវមានកម្រិត ស្មុគស្មាញ និងចំណាយពេលវេលាច្រើន។ ដូច្នេះ ដើម្បីលើកស្ទួយវិស័យស្រាវជ្រាវដែលរាជរដ្ឋាភិបាលចាត់ទុកជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ វិទ្យាស្ថានកាឌីសំណូមពរដល់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាអាណាព្យាបាល មេត្តាពិនិត្យលទ្ធភាពដោះស្រាយ ឬកាត់បន្ថយនូវបញ្ហាទាំង៣ខាងលើ។

## ៥. ទិសដៅយុទ្ធសាស្ត្រ

ដើម្បីរួមចំណែកធ្វើឲ្យសម្រេចគោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មក្នុងការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជានឹងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គភាពស្រាវជ្រាវជាតិនិងអន្តរជាតិ មន្ទីរកសិកម្មរាជធានី ខេត្ត អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងក្រៅស្រុកនានា ដៃគូអភិវឌ្ឍន៍ ក៏ដូចជាមួយកសិករ ដើម្បីអនុវត្តសកម្មភាពស្រាវជ្រាវតាមអនុកម្មវិធីចម្បងចំនួនបីរបស់ខ្លួនគឺ៖

**អនុកម្មវិធីទី១.១៨៖ ស្រាវជ្រាវដើម្បីបង្កើនផលិតភាពកសិកម្ម:** ក្នុងគោលបំណងជំរុញការស្រាវជ្រាវបច្ចេកវិទ្យាបង្កើនផលិតភាពដំណាំប្រកបដោយនិរន្តរភាព តាមរយៈការបង្កើនការអភិរក្សនិងប្រើប្រាស់ពូជដំណាំ ការបញ្ចេញពូជដំណាំអតិផល និងគុណភាពល្អព្រមទាំងធន់នឹងកត្តាជីវៈនិងអជីវៈ ការគ្រប់គ្រងដំណាំ និងបច្ចេកទេសមុននិងក្រោយប្រមូលផល។

Cambodian Agricultural Research and Development Institute (CARDI)

អនុកម្មវិធីទី១.១៩៖ ស្រាវជ្រាវដើម្បីពិពិធកម្មនិងផ្សព្វផ្សាយកសិកម្មៈ គោលបំណងគឺ អភិវឌ្ឍនិងផ្ទេរបង្កបច្ចេកទេសដាំដុះដំណាំសមស្របតាមលក្ខខណ្ឌដាំដុះនិងសង្គមសេដ្ឋកិច្ចរបស់កសិករ សំដៅធ្វើប្រព័ន្ធនិរន្តរភាពពិពិធកម្មដំណាំជាមូលដ្ឋានដែលមានផលចំណេញខ្ពស់។

អនុកម្មវិធីទី១.២០៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍធនធានមនុស្សផ្នែកពិសោធន៍ស្រាវជ្រាវៈ សំដៅបង្កើនសមត្ថភាពនិងទេពកោសល្យរបស់អ្នកគ្រប់គ្រង អ្នកស្រាវជ្រាវ សេវាទ្រទ្រង់ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ការអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិទ្យា។

៙★៙

Cambodian Agricultural Research and Development Institute(CARDI)

## ១. អនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល (Recommendation of Prime Minister)



ក្នុងទិវាស្រូវ–អង្ករ រៀបចំដោយសហព័ន្ធស្រូវ–អង្ករកម្ពុជា ដែលប្រារព្ធនៅអូតែលសុខានាថ្ងៃទី២៥ ខែមករា ឆ្នាំ ២០១៥ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ពិនិត្យស្រូវ–អង្កររបស់ពូជស្រូវល្អៗបានបញ្ចេញដោយវិទ្យាស្ថានកាឌី ដែលស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងផ្តល់អនុសាសន៍ឲ្យវិទ្យាស្ថានកាឌី ត្រូវបន្តផលិតគ្រាប់ពូជសុទ្ធគ្រើះរបស់ពូជដំណាំដែលបានបញ្ចេញផ្គត់ផ្គង់ដល់វិស័យឯកជននិងអ្នកពាក់ព័ន្ធ ដើម្បីផលិតគ្រាប់ពូជចំណាត់ថ្នាក់បន្តទៀតផ្គត់ផ្គង់ជូនកសិករ។

During Rice Forum organized by the Cambodian Rice Federation held on 25 January, 2016 at Sokha Hotel, Prime Minister visited rice varieties released by CARDI of the MAFF and MEF and recommended that CARDI should continues to produce foundation seeds to supply to seed producers for continuously producing other seed classes selling to farmers.

Cambodian Agricultural Research and Development Institute(CARDI)

## ២. យន្តការតម្រង់ទិសរបស់វិទ្យាស្ថានកាឌី (Directed mechanism for CARDI)



វិទ្យាស្ថានកាឌីអនុវត្តតាមផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤–២០១៨ដែលបានដាក់ឲ្យប្រើប្រាស់ (CARDI is implementing Agricultural Strategic Development Plan 2014-2018)។

Cambodian Agricultural Research and Development Institute(CARDI)



បេសកកម្មនិងប្រតិបត្តិការរបស់វិទ្យាស្ថានកាឌី ឋិតនៅក្រោមការណែនាំនិងតម្រង់ទិសរបស់ក្រុមប្រឹក្សាភិបាល (CARDI’s mission and implementation are under supervision of its Board of Director)។

### ៣. ការគាំទ្ររបស់ថ្នាក់ដឹកនាំក្រសួងលើសមិទ្ធផលរបស់វិទ្យាស្ថានកាឌី (MAFF management support on CARDI achievements)




Cambodian Agricultural Research and Development Institute(CARDI)

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអភិរក្សពូជដំណាំរយៈពេលយូររវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង រដ្ឋបាលអភិវឌ្ឍន៍ជនបទ និងការដាក់បញ្ចូលពូជស្រូវចំនួន២១៧បញ្ជីក ដែលបានប្រមូលនិងវាយតម្លៃដោយវិទ្យាស្ថានកាឌី ទៅក្នុងធនាគារពន្ធនៅរដ្ឋបាលអភិវឌ្ឍន៍ជនបទនៃសាធារណរដ្ឋកូរ៉េ ។
Signing ceremony on Letter of Agreement between the Ministry of Agriculture, Forestry and Fisheries of the Kingdom of Cambodia and the Rural Development Administration of the Republic of Korea (RDA) to maintain a safe duplicate of Cambodian collection of plant genetic resources at RDA Genebank with first depositing of 217 rice accessions.







ការចុះពិនិត្យ តាមដានការដុះលូតលាស់ ការពិភាក្សាជាមួយកសិករ ការភ្លក់រសជាតិបាយ និងមតិផ្តាំផ្ញើរជូនដល់កសិករចូលរួមក្នុងទិវាស្រែបង្ហាញពូជស្រូវបញ្ចេញថ្មី ដោយថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
Monitoring and evaluation of growth performance, tasting cooked rice and discussing with farmers during farmer field day of new released variety by MAFF’s Leader.



ការប្រារព្ធទិវានារីអន្តរជាតិលើកទី១០៤ ក្រោមប្រធានបទ˝ ដំណើរឆ្ពោះទៅមុខ៖ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥˝ (International Women Day ceremony)។

Cambodian Agricultural Research and Development Institute(CARDI)

## ៤. ការរៀនសូត្រនិងចែករំលែកបទពិសោធន៍ (Sharing of experiences)



ថ្នាក់ដឹកនាំវិទ្យាស្ថានបានទទួលជួបបង្ហាញនូវលទ្ធផលការងារពិសោធន៍ស្រាវជ្រាវ និងពិភាក្សាជាមួយគណៈប្រតិភូភ្ញៀវជាតិ និងអន្តរជាតិចំនួន៥៧លើក ដែលមានភ្ញៀវសរុប២៦៥នាក់ (CARDI's management met with national and international guests 57 times with 265 people to brief research results and activities, and to discuss on matters arising by the guests)។



ការប្រារព្ធខួបលើកទី១៦ នៃការបង្កើតវិទ្យាស្ថានកាឌី (16th CARDI Anniversary ceremony)។

Cambodian Agricultural Research and Development Institute (CARDI)

## ៨. ការចូលរួមក្នុងគណៈកម្មការស្រាវជ្រាវអន្តរជាតិ (Contribution in International Research Committees)













Cambodian Agricultural Research and Development Institute(CARDI)

ចូលរួមកិច្ចប្រជុំនៃគណៈកម្មការស្រាវជ្រាវអន្តរជាតិនានា ដែលថ្នាក់ដឹកនាំរបស់វិទ្យាស្ថានកាឌីជាសមាជិក ដូចជា៖ (១) ប្រជុំក្រុមប្រឹក្សានយោបាយរបស់អេស៊ីអាយអេអរ (រូបភាព១) (២) គណៈកម្មការដឹកនាំនៃក្រុមប្រឹក្សាជំនាញសម្រាប់ដំណាំស្រូវក្នុងបរិស្ថានមិនអំណោយផល (៣) ប្រជុំក្រុមប្រឹក្សាសម្រាប់ភាពជាដៃគូរលើការស្រាវជ្រាវដំណាំស្រូវក្នុងអាស៊ី (រូបភាព៣) និងអនុគណៈកម្មការជីវបច្ចេកវិទ្យាអាស៊ានជាដើម (រូបភាព៤) [Management, as a member of committee, participated in annual meeting of (1) Policy Advisory Committee of Australian Center for International Agricultural Research, PAC-ACIAR, (2) Consortium for Unfavorable Rice Environments, CURE; (3) Council for Partnership on Rice Research in Asia, CORRA; and (4) ASEAN Sub-Committee on Biotechnology; etc.]។



ពិធីប្រគល់–ទទួលគ្រឿងចក្រកសិកម្មពីគម្រោងជំរុញផលិតភាពកសិកម្មនិងប្រព័ន្ធស្រោចស្រពជនបទ និងការប្រើប្រាស់ [Handling of machineries supported by Rural Irrigation and Agricultural Productivity Improvement Project (RIAPIP)]។



មន្ត្រី និយោជិកដែលទទួលបានប្រកាសនីយបត្រភក្តីភាពក្នុងការបំពេញភារកិច្ចជូនវិទ្យាស្ថានគម្រប់រយៈពេល៥ឆ្នាំ ១០ឆ្នាំ និង១៥ឆ្នាំ ក្នុងពិធីខួបលើកទី១៦ នៃការបង្កើតវិទ្យាស្ថានកាឌី (CARDI staff and management received certificate of completion of 5 years, 10 years and 15 years working for CARDI)។

## ៦. ការអភិវឌ្ឍពូជដំណាំ (Crop Varietal Improvement)



សកម្មភាពចុះប្រមូលពូជដំណាំនិងសាកសួរព័ត៌មានគ្រឹះពីកសិករដើម្បីអភិរក្សនិងប្រើប្រាស់ (Collection of crop varieties and passport data from farmers for conservation and utilization) ។

Cambodian Agricultural Research and Development Institute(CARDI)



ដំណាំត្រសក់ស្រូវ ម្ទេស និងស្រូវដែលប្រមូលបាន ត្រូវបានដាំវាយតម្លៃកំណត់លក្ខណៈ និងយកគ្រាប់ពូជរក្សាទុក (Collected melons, chilies and rice were planted for evaluation, characterization and having seeds for conservation)។

Cambodian Agricultural Research and Development Institute(CARDI)



ការដាំពង្រីកគ្រាប់ពូជ និងទិវាចម្ការបង្ហាញរួមទាំងការភ្លក់រសជាតិរបស់ពោតដំណើប ស៊ីអឹម១ (Seed increase and famer field day including tasting of boiled glutinous maize CM1)។



ការពិនិត្យជំងឺលើស្រទ្បាយសណ្តែកបាយក្នុងពិសោធន៍នៅខេត្តតាកែវ និងផលរបស់ស្រទ្បាយសណ្តែកដី (Observation of diseases on mungbean lines in experiment at Takeo and yield performance of peanut line)។




ការចុះវាយតម្លៃស្រទ្បាយប៉េងប៉ោះក្នុងពិសោធន៍ និងពិសោធន៍ពូជឪទ្បឹក (Evaluation of tomato lines in experiment and watermelon varietal experiment)។



ការដាំដុះជ្រើសរើសស្រទ្បាយស្រូវបង្កាត់ ការថែរទាំ ការកត់ត្រាទិន្នន័យពិសោធន៍ និងការជជែកពិភាក្សាអំពីវិធីសាស្ត្រពិសោធន៍រកភាពធន់នឹងការរាំងស្ងួតជាមួយអ្នកវិទ្យាសាស្ត្រអ៊ីរី (Planting rice breeding lines, management of experiment, data recording and discussion with IRRI Scientist on screening method for drought)។

Cambodian Agricultural Research and Development Institute(CARDI)



ការពិនិត្យលក្ខណៈស្រទ្បាយស្រូវស្មាច់ ការចុះពិនិត្យបញ្ហាស្រូវនិងផ្តល់នូវដំណោះស្រាយតាមសំណើររបស់កសិករ នៅឃុំស្មោងខាងជើង ស្រុកកំចាយមារ ការពិនិត្យមើលការដុះលូតលាស់របស់ពូជស្រូវផ្ការំដួល ផ្ការំដេង និងផ្ការមៀតនៅតំបន់ទឹកប្រៃស្រុកបទុមសាគរ ខេត្តកោះកុង និងទិវាស្រែនៅខេត្តកំពត (Observing characters of Smach pure line, identifying problem and providing solution in response to request by farmers in Smaong Khang Cheung Commune, Kamchay Mear district, monitoring performance of Phka Rumduol, Phka Rumdeng and Phka Romeat demonstrating on coastal area in Botum Sako district, Kah Kong; and farmer field day in Kampot)។




ផលិតកម្មគ្រាប់ពូជស្រូវរុក្ខជម្រើសវិទូ គ្រាប់ពូជសុទ្ធគ្រឹះ និងគ្រាប់ពូជសុទ្ធល្អ (Seed production of breeder seed, foundation seed and good seed of rice)។

Cambodian Agricultural Research and Development Institute (CARDI)

## ៧. ការគ្រប់គ្រងជីជាតិដី (Soil Nutrient Management)




ការរៀបចំពិសោធន៍ស្តីពីការកំណត់សំណើមសមស្របសម្រាប់លក្ខខណ្ឌដំណុះដំណាំសំខាន់ៗមួយចំនួន (Set up field trials to determine the optimum soil moisture content for crops germination) ។




ការចុះពិនិត្យតាមដានស្ថានភាពលូតលាស់របស់ដំណាំដំឡូងមីក្នុងពិសោធន៍លើចម្ការកសិករ និងការតម្លើងស្ថានីយអាកាសធាតុស្វ័យប្រវត្តិក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង (Evaluation crop growth and installing a main weather station on farmer field at Phnom Preuk district, Battambang province)។




ការតម្លើងឧបករណ៍តាមដានសំណើមដីស្វ័យប្រវត្តិនៃពិសោធន៍នៅក្នុងវិទ្យាស្ថាន (Installing automatic soil moisture monitoring instrument at CARDI trial field)។

Cambodian Agricultural Research and Development Institute(CARDI)



ការធ្វើចំណាត់ថ្នាក់ដីដាំដុះស្រូវនៅតាមដំបន់ស្រោចស្រពសំខាន់ៗ (Rice soil classification for the main sub-irrigation systems)។



ការរៀបចំប្លង់ពិសោធន៍ដី និងការរៀបចំត្រងយកដីដែលហូរច្រោះនៅចម្ការដំឡូងមី (Preparation of field trial and collection of soil erosion on cassava farm)។

Cambodian Agricultural Research and Development Institute(CARDI)



ការប្រមូលទិន្នន័យសំខាន់ៗដែលមានឥទ្ធិពលលើវាយតម្លៃការលូតលាស់ និងទិន្នផលដំណាំ (Data collection of the critical parameters for determining crop growths and yields)។



ការលាយសូលុយស្យុង និងវិភាគគីមីនៅមន្ទីរពិសោធន៍ដី និងទឹក (Solution preparation and chemical analysis in Soil and Water Laboratory)។

## ៨. ការគ្រប់គ្រងកត្តាចង្រៃ (Pest Management)



ការចុះតាមដាននិងកត់ត្រាកត្តាចង្រៃលើដំណាំ ការរៀបចំពិសោធន៍ប្រសិទ្ធភាពថ្នាំលើខ្យងពណ៌មាសនិងសត្វក្នុងស្រែ និងការធ្វើរោគវិនិច្ឆ័យប្រភេទមេរោគផ្សិត (Monitoring pest on crops, establishing experiment on golden apple snail control, and diagnostic of fungi)។

Cambodian Agricultural Research and Development Institute(CARDI)



ទិវាច្រូតស្រូវរបស់វិទ្យាស្ថានកាឌីនិងមជ្ឈមណ្ឌលកូព្យ៉ា (Rice Harvesting Day of CARDI and KOPIA)។

## ៩. ការប្រើប្រាស់គ្រឿងយន្តកសិកម្ម (Utilization of Agricultural Mechanization)



ការសិក្សាអំពីប្រសិទ្ធភាពនៃការបំបែកស្រទាប់បាតនង្គ័លលើការដុះលូតលាស់និងផលរបស់សណ្តែកបាយលើដីស្រែដែលប្រមូលផលស្រូវវស្សារួច (Study on effect of breaking hard pan of rainfed lowland soil on mungbean after harvesting wet season rice)។



ស្រែបង្ហាញអំពីការដាំដុះស្រូវដោយឧបករណ៍ដាំគ្រាប់ស្ងួតដែលកែច្នៃដោយវិទ្យាស្ថានកាឌី (Field demonstration of Cambodian dry seeder on rice)។

Cambodian Agricultural Research and Development Institute(CARDI)



ការសិក្សាអំពី ការបាត់បង់ក្នុងគ្រាដឹកជញ្ជូនពីចម្ការក្នុងស្រុកស្អាងទៅដល់ផ្សារទីរួមខេត្តសៀមរាប (Study on post-harvest loss by transportation from farmer field to final market in Siem Reap municipality)។



ការពន្យល់អំពីលក្ខណៈរបស់ពូជស្រូវនិងលក្ខខណ្ឌដាំដុះ ព្រមទាំងការប្រគល់គ្រាប់ពូជស្រូវជូនកសិករ (Explaining of main characteristics and growing conditions before delivering seeds of rice varieties to farmers)។



ការបណ្តុះបណ្តាលកសិករដែលទទួលគ្រាប់ពូជស្រូវទៅតាមដំណាក់កាលសំខាន់ៗនៃបង្គុំបច្ចេកទេស (Farmer training at main stages of technology packages)។

Cambodian Agricultural Research and Development Institute(CARDI)



ទិវាស្រែបង្ហាញអំពីលទ្ធផលបង្កុំបច្ចេកទេស (Farmer field days on results of technology package)។



ការចុះសម្ភាសន៍ជាមួយកសិករម្នាក់ៗអំពីការទទួលយកបច្ចេកវិទ្យារបស់វិទ្យាស្ថានកាឌី (Interviewing individual farmer on adoption of CARDI technology)។



ការប្រមូលព័ត៌មានពីក្រុមតំណាងកសិករអំពីបញ្ហានិងតម្រូវការ (Farmer participatory apraisal to identy problems and needs)។

Cambodian Agricultural Research and Development Institute (CARDI)



ការប្រមូលព័ត៌មានពីទីផ្សារ (Collection of market information)។



សន្និបាតបូកសរុបការងារវិទ្យាស្ថានប្រចាំឆ្នាំ ២០១៥ (CARDI Staff Assembly, 2015)។



វគ្គបណ្តុះបណ្តាលផ្សេងៗ (Different training courses provided by CARDI)។

Cambodian Agricultural Research and Development Institute(CARDI)



វគ្គបណ្តុះបណ្តាលផ្សេងៗ (Different training courses provided by CARDI)។

Cambodian Agricultural Research and Development Institute(CARDI)



ទស្សនកិច្ចសិក្សានៃក្រុមនិស្សិត ភ្ញៀវជាតិ និងអន្តរជាតិនៅវិទ្យាស្ថានកាឌី ( Study tour of studnets, national and Internaltional guests at CARDI)។